**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់សមាសភាពនៃគណៈកម្មាធិការមត៌កមនុស្សរស់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានកំណត់សមាសភាពនៃគណៈកម្មាធិការមត៌កមនុស្សរស់ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២. ឯកឧត្តម | **ច័ន្ទ តានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. ឯកឧត្តម | **ឈន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច | អនុប្រធាន |
| ៤. ឯកឧត្តម | **សំរ៉ាំង កំសាន្ត** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៥. ឯកឧត្តម | **សុខ ផេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦. លោកជំទាវ | **ឃុន រចនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ៧. ឯកឧត្តម | **សេង សុម្មុនី** | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ៨. លោកជំទាវ | **ឈី ខិដ្ឋ៉ា** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិកា |
| ៩. លោកជំទាវ | **ចម និម្មល** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ១០. ឯកឧត្តមបណ្ឌិត | **ទូ ចាន់សុភី** | ប្រធានវិទ្យាស្ថានវប្បធម៌នៃរាជបណ្ឌិតសភាកម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ១១.ឯកឧត្តម | **ពេជ្រ ឆុំក្រមិល** | ទីប្រឹក្សាអមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២.ឯកឧត្តម | **ស៊ិន សុខ** | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១៣.ឯកឧត្តម | **ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិក |
| ១៤.លោក | **សួន សុវណ្ណា** | អគ្គលេខាធិការស្ដីទីនៃគណៈកម្មការជាតិបេតិកភណ្ឌពិភពលោក | សមាជិក |

**មាត្រា២.-**

គណៈកម្មាធិការមត៌កមនុស្សរស់ត្រូវអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា ៩នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្ដីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ